# ព្រះរាជក្រម

នស / រកម / ១២១២ / ០១០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១២ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ នាសម័យប្រជុំលើកទី២ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់

# ស្តីពី

# ហិរញ្ញវត្ថុសម្រាប់

# ការគ្រប់គ្រងឆ្នាំ ២០១៣

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL



p

# ជំពូកទី ១
# ថវិកាថ្នាក់ជាតិ

**មាត្រា ១.-**

ត្រូវបានអនុញ្ញាតសម្រាប់ឆ្នាំ ២០១៣ ឲ្យប្រមូលចំណូលបង់ចូលថវិកាថ្នាក់ជាតិនូវពន្ធដារ ភាគទាន អាករ ផលទុន និងចំណូលនានា ព្រមទាំងធ្វើឲ្យសម្រេចនូវឧបត្ថម្ភកធនវិនិយោគ និងការខ្ចី តាមមាតិកាថវិកា ដូចមានចែងក្នុងតារាង "ក" ដែលភ្ជាប់មកជាមួយច្បាប់នេះ ក្នុងទឹកប្រាក់សរុបចំនួន ១២ ០៩៥ ០៧៣,៣ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណូលចរន្ត..........................................................៨ ៤៧៣ ៧៧៨,៣ លានរៀល
- ចំណូលមូលធន.......................................................៣ ៤៥០ ០២១ លានរៀល
  - \+ ចំណូលមូលធនក្នុងប្រទេស......................................៨២ ០០០ លានរៀល
  - \+ ចំណូលមូលធនក្រៅប្រទេស...................................៣ ៣៦៨ ០២១ លានរៀល
    - មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ...២២២ ០២១ លានរៀល
    - វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស...៣ ១៤៦ ០០០ លានរៀល
- ប្រើប្រាស់បញ្ញើរាជរដ្ឋាភិបាល.........................................១៧១ ២៧៤ លានរៀល

**មាត្រា ២.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ត្រូវបានកំណត់ស្មើនឹង ១២ ០៩៥ ០៧៣,៣ លានរៀល ដែលត្រូវបានបែងចែកដូចតទៅ ៖

- ចំណាយចរន្ត.........................................................៧ ២១២ ៥៧៣,៣ លានរៀល
- ចំណាយមូលធន.......................................................៤ ៨៨២ ៥០០ លានរៀល

ក-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស...១ ៤៥៦ ៥០០ លានរៀល

- ដោយថវិកាថ្នាក់ជាតិ...........................................១ ១៧១ ៥០០ លានរៀល
  - គម្រោងវិនិយោគផ្ទាល់..................................៩៥១ ៥០០ លានរៀល
  - បដិភាគក្នុងការអនុវត្តគម្រោងហិរញ្ញប្បទានក្រៅប្រទេស.................................................................២២០ ០០០ លានរៀល
- ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ.................................................................២៨៥ ០០០ លានរៀល

ខ-វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស...៣ ១៤៦ ០០០ លានរៀល

គ-ការទូទាត់ការខ្ចី.................................................២៨០ ០០០ លានរៀល

**មាត្រា ៣.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយចរន្តថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ត្រូវបានកំណត់ស្មើនឹង ៧ ២១២ ៥៧៣,៣ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ និងទៅតាមប្រភេទចំណាយ ដូចមានចែងក្នុងតារាង "ខ" ដែលភ្ជាប់មកជាមួយច្បាប់នេះ។

**មាត្រា ៤.-**

ចំនួនទឹកប្រាក់នៃឥណទានមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស សម្រាប់ការគ្រប់គ្រងពីឆ្នាំ ២០១៣ ដល់ ២០១៥ ត្រូវបានកំណត់ស្មើនឹង ១០ ៧២៧ ៦៣៥ លានរៀល ។

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ តាមគម្រោង និងតាមឆ្នាំ ដូចមានចែងក្នុងតារាង "គ១" និងតារាង "គ២" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

**មាត្រា ៥.-**

ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានភ្ជាប់សន្យា និងឥណទានទូទាត់សម្រាប់ចំណាយមូលធនថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ត្រូវបានកំណត់ដូចខាងក្រោម ៖

- ឥណទានភ្ជាប់សន្យា..........................................៥ ០៤៩ ១២០ លានរៀល
- ឥណទានទូទាត់..................................................៤ ៨៨២ ៥០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកដូចតទៅ :

ក. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស

- ឥណទានភ្ជាប់សន្យា..................................១ ៤៥៦ ៥០០ លានរៀល
- ឥណទានទូទាត់..........................................១ ៤៥៦ ៥០០ លានរៀល

ខ. វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស

- ឥណទានភ្ជាប់សន្យា..................................៣ ៣១២ ៦២០ លានរៀល
- ឥណទានទូទាត់..........................................៣ ១៤៦ ០០០ លានរៀល

គ. ការទូទាត់ការខ្ចី

- ឥណទានភ្ជាប់សន្យា......................................២៨០ ០០០ លានរៀល
- ឥណទានទូទាត់..............................................២៨០ ០០០ លានរៀល

ឥណទាននេះត្រូវបានបែងចែកតាមក្រសួងនីមួយៗ និងតាមស្ថាប័នប្រហាក់ប្រហែលនីមួយៗ ដូចមានចែងក្នុងតារាង "ឃ" ដែលភ្ជាប់មកជាមួយច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

Kd



p

**មាត្រា ៦.-**

តុល្យភាពនៃថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ដែលបានរៀបចំនៅក្នុងតារាង "ក" ស្តីពីចំណូលថវិកាថ្នាក់ជាតិ និងតារាង "ខ" ស្តីពីចំណាយថវិកាថ្នាក់ជាតិ ត្រូវបានបង្ហាញនៅក្នុងតារាងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិដូចខាងក្រោម ៖

ឯកតា:លានរៀល

| កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ | ចំនួនទឹកប្រាក់ | តុល្យភាព/ហិរញ្ញប្បទាន |
|---|---|---|
| I. ចំណូលក្នុងប្រទេស | ៨ ៥៥៥ ៧៧៨,៣ | |
| ១. ចំណូលចរន្ត | ៨ ៤៧៣ ៧៧៨,៣ | |
| ២. ចំណូលមូលធនក្នុងប្រទេស | ៨២ ០០០ | |
| II. សរុបចំណាយថវិកា | ១១ ៨១៥ ០៧៣,៣ | |
| ១. ចំណាយចរន្ត | ៧ ២១២ ៥៧៣,៣ | |
| ២. ចំណាយមូលធន (មិនគិតការទូទាត់ការខ្ចី) | ៤ ៦០២ ៥០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្នុងប្រទេស | ១ ៤៥៦ ៥០០ | |
| + ដោយថវិកាថ្នាក់ជាតិ | ១ ១៧១ ៥០០ | |
| - គម្រោងវិនិយោគផ្ទាល់ | ៩៥១ ៥០០ | |
| - បដិភាគ | ២២០ ០០០ | |
| + ដោយមូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | ២៨៥ ០០០ | |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | ៣ ១៤៦ ០០០ | |
| អតិរេកនៃថវិកាចរន្ត ( I.១ -II.១ ) | | +១ ២៦១ ២០៥ |
| ឱនភាពសរុបនៃថវិកាថ្នាក់ជាតិ (I-II ) | | -៣ ២៥៩ ២៩៥ |
| III. ហិរញ្ញប្បទាននៃឱនភាព | | +៣ ២៥៩ ២៩៥ |
| ១. ហិរញ្ញប្បទានក្រៅប្រទេស | | +៣ ០៨៨ ០២១ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +២២២ ០២១ |
| • វិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេស | | +៣ ១៤៦ ០០០ |
| • ការទូទាត់ការខ្ចី | | -២៨០ ០០០ |
| ២. ហិរញ្ញប្បទានក្នុងប្រទេស | | +១៧១ ២៧៤ |
| • បញ្ញើរាជរដ្ឋាភិបាល | | -២១ ៧០៥ |
| • មូលនិធិទ្រទ្រង់ថវិកាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍ | | +១៩២ ៩៧៩ |

## ជំពូកទី ២
## ការខ្ចី និងការធានារបស់រដ្ឋ

**មាត្រា ៧.-**

សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ អនុម័តយល់ព្រមឲ្យរាជរដ្ឋាភិបាលខ្ចីប្រាក់ពីគេក្នុងកម្រិត ៦០០ ០០០ ០០០ S.D.R. (ប្រាំមួយរយលានអេសដេអ៊ែរ) ។

ការខ្ចីដែលត្រូវចុះកិច្ចសន្យាក្នុងកម្រិតខាងលើ ត្រូវមានលក្ខណៈជាការខ្ចីសម្បទានដែលត្រូវសងវិញជាមួយការប្រាក់អនុគ្រោះ ។

នៅក្នុងលក្ខខណ្ឌនេះរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអ្នកមានសិទ្ធិស្របច្បាប់តែមួយគត់តាមការប្រទានសិទ្ធិជាលាយលក្ខណ៍អក្សររបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាក្នុងការចុះហត្ថលេខាលើការខ្ចីជាគុណប្រយោជន៍នៃថវិកាទូទៅរបស់រដ្ឋ ឬ លើការធានារបស់រដ្ឋហើយត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តនៃការខ្ចី និងការធានានេះជូនរដ្ឋសភា និងព្រឹទ្ធសភារៀងរាល់ ៦ ខែម្តង ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានការឯកភាពពីធនាគារជាតិនៃកម្ពុជា ត្រូវបានទទួលការអនុញ្ញាតឲ្យបោះផ្សាយបណ្ណរតនាគារក្នុងកម្រិតទឹកប្រាក់ដែលមានស្តុកចំនួន ១០០ ០០០ ០០០ ០០០ រៀល (មួយរយពាន់លានរៀល) ដើម្បីដោះស្រាយតម្រូវការជាបន្ទាន់ខាងសាច់ប្រាក់ ។ លក្ខខណ្ឌនៃការលក់បណ្ណរតនាគារនេះត្រូវកំណត់ដោយលិខិតបទដ្ឋានស្របច្បាប់ ។

**មាត្រា ៩.-**

សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ អនុម័តយល់ព្រមឲ្យរាជរដ្ឋាភិបាលអនុញ្ញាតឲ្យអគ្គិសនីកម្ពុជាខ្ចីនូវទឹកប្រាក់ចំនួន ១២១ ៥០០ ០០០ ០០០ រៀល (មួយរយម្ភៃមួយពាន់ប្រាំរយលានរៀល) ។

**មាត្រា ១០.-**

សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ អនុម័តយល់ព្រមឲ្យរាជរដ្ឋាភិបាលបោះផ្សាយសញ្ញាបណ្ណដើម្បីបំពេញដើមទុនជូនក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត "កម្ពុជាឡៃហ្វ" និងក្រុមហ៊ុនធានារ៉ាប់រងបន្តកម្ពុជា "កម្ពុជា រី" ក្នុងកម្រិតទឹកប្រាក់ចំនួន ២២ ០៨០ ០០០ ០០០រៀល (ម្ភៃពីរពាន់ប៉ែតសិបលានរៀល) ។

ចរិតលក្ខណៈរបស់សញ្ញាបណ្ណនឹងត្រូវកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយមានកិច្ចសហការពីធនាគារជាតិនៃកម្ពុជា ។

**មាត្រា ១១.-**

មិនអនុញ្ញាតឲ្យក្រសួង ឬ ស្ថាប័នសាធារណៈណាមួយចំណុះរដ្ឋមានសិទ្ធិចុះហត្ថលេខាក្រោមរូបភាពបោះផ្សាយមូលបត្ររយៈពេលវែង មធ្យម ខ្លី ឬ ឥណទានអ្នកផ្គត់ផ្គង់ ឬ ចុះកិច្ចសន្យាក្រោមរូបភាពទទួលបន្ទុកខ្ចី ឬ ការធានាកិច្ចសន្យាដែលបានចុះហត្ថលេខាដោយស្ថាប័នសាធារណៈ ឬ ឯកជន ឬ ចុះកិច្ចសន្យាក្រោមរូបភាពកិច្ចសន្យាផ្សេងៗទៀត ដែលត្រូវសងបំណុលតាមកាលកំណត់ ឬ តាមឆ្នាំដែលស្ថិតនៅក្រៅការអនុញ្ញាតនៃច្បាប់ហិរញ្ញវត្ថុ និងលក្ខខណ្ឌទាំងឡាយដែលច្បាប់នេះបានកំណត់នោះទេ ។

## ជំពូកទី ៣
## បទប្បញ្ញត្តិស្តីពីពន្ធប្រថាប់ត្រា
## និងការគ្រប់គ្រងបរធនបាលកិច្ចហិរញ្ញវត្ថុ

### ផ្នែកទី ១
### បទប្បញ្ញត្តិមួយចំនួនស្តីពីពន្ធប្រថាប់ត្រា

**មាត្រា ១២.-**

មាត្រា ៤០ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ១១ ន.ស.៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានកែប្រែដូចតទៅ ៖

មាត្រា ៤០ ថ្មី.- ពន្ធប្រថាប់ត្រា ត្រូវបានកំណត់តាមអត្រាដូចខាងក្រោម ៖

១. ៤ % នៃតម្លៃអចលនទ្រព្យចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យជាសំណង់ ឬ/និងដី ឬ ការដាក់ភាគហ៊ុនជាអចលនទ្រព្យក្នុងក្រុមហ៊ុន ។

២. ៤ % នៃតម្លៃមធ្យោបាយដឹកជញ្ជូន ឬ យានយន្តចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់មធ្យោបាយដឹកជញ្ជូន ឬ យានយន្តគ្រប់ប្រភេទ ។

៣. ០,១ % នៃតម្លៃភាគហ៊ុនចំពោះការផ្ទេរចំណែកណាមួយ ឬ ទាំងស្រុងនៃភាគហ៊ុនរបស់ក្រុមហ៊ុន ។

៤. ០,១ % នៃតម្លៃចុះកិច្ចសន្យាចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬ សេវាដែលប្រើប្រាស់ថវិការដ្ឋ ។

៥. ១ ០០០ ០០០ រៀល (មួយលានរៀល) ចំពោះលិខិតមានលក្ខណៈគតិយុត្តិ ជាអាទិ៍ លិខិតស្តីពីការបង្កើតក្រុមហ៊ុន លិខិតស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា និងលិខិតស្តីពីការបិទក្រុមហ៊ុន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL
7/29
Kol
p

**មាត្រា ១៣.-**

ពន្ធប្រថាប់ត្រា ត្រូវបានលើកលែងនិងអនុគ្រោះដូចខាងក្រោម ៖

១. ការទទួលកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់ដីក្នុងលក្ខណៈសម្បទានពីរាជរដ្ឋាភិបាល ត្រូវបានលើកលែងពន្ធប្រថាប់ត្រា ។

២. ការទទួលកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យពីញាតិ ត្រូវបានអនុគ្រោះឲ្យដកចេញពីតម្លៃគិតពន្ធប្រថាប់ត្រាចំនួន ៖

- ២០០ ០០០ ០០០ រៀល (ពីររយលានរៀល) ចំពោះសន្តតិកម្ម
- ១០០ ០០០ ០០០ រៀល (មួយរយលានរៀល) ចំពោះប្រទានកម្ម

## ផ្នែកទី ២
## ការគ្រប់គ្រងបរធនបាលកិច្ច ហិរញ្ញវត្ថុក្នុងវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ

**មាត្រា ១៤.-**

អនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាបញ្ញត្តិករបរធនបាលកិច្ចហិរញ្ញវត្ថុ ដើម្បីគ្រប់គ្រង និងថែរក្សាមូលនិធិជាបរធន ដែលរាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងជាមួយដៃគូអភិវឌ្ឍ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ ។

បរធនបាលកិច្ចហិរញ្ញវត្ថុនេះត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៤
## និយ័តភាវូបនីយកម្មនៃកិច្ចប្រតិបត្តិការ ថវិកាបន្ថែមសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២

**មាត្រា ១៥.-**

ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ៦១ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ត្រូវបានយល់ព្រមជាគោលការណ៍ផ្តល់ឥណទានថវិកាបន្ថែមដល់ថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ ជាទឹកប្រាក់ចំនួន ១០៥ ០០០ ០០០ ០០០ រៀល (មួយរយប្រាំពាន់លានរៀល) សម្រាប់ផ្តល់មូលនិធិធានាឥណទានក្នុងការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ។

ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១២ នឹងត្រូវអនុម័តនូវចំនួនទឹកប្រាក់ជាក់ស្តែងនៃកិច្ចប្រតិបត្តិការថវិកាបន្ថែមខាងលើនេះ ។

## ជំពូកទី ៥
## ថវិកាថ្នាក់ក្រោមជាតិ

**មាត្រា ១៦.-**

ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃមាត្រា ៨៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ និងបទប្បញ្ញត្តិនៃមាត្រា ៣៥ និងមាត្រា ៥៤ នៃច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១ ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៣ ត្រូវបានកំណត់ដូចខាងក្រោម ៖

**ក.ថវិការបស់រដ្ឋបាលរាជធានី ខេត្ត**

- សរុបចំណូលថវិកា..................................................៥២០ ២២១ លានរៀល
  - \+ សរុបចំណូលចរន្ត..............................................៤៣១ ៩៣៥ លានរៀល
    - -ចំណូលសារពើពន្ធ.......................................៤០៨ ៧២៧ លានរៀល
    - -ចំណូលមិនមែនសារពើពន្ធ...............................២៣ ២០៨ លានរៀល
  - \+ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ...............................៨៨ ២៨៦ លានរៀល

  (ក្នុងនោះឧបត្ថម្ភសម្រាប់មូលនិធិសង្កាត់ចំណុះរាជធានី ១៨ ០១៦ លានរៀល)
- សរុបចំណាយថវិកា..................................................៥២០ ២២១ លានរៀល
  - \+ចំណាយចរន្ត.....................................................៣៨៤ ៧៩៨ លានរៀល
  - \+ចំណាយមូលធន...............................................១១៧ ៤០៧ លានរៀល
  - \+ចំណាយសង្កាត់ចំណុះរាជធានី...............................១៨ ០១៦ លានរៀល

**ខ.ថវិការបស់រដ្ឋបាលក្រុង ស្រុក**

- សរុបចំណូលថវិកា..................................................៨០ ៣២១ លានរៀល
  - \+សរុបចំណូលចរន្ត...................................................១ ០៥០ លានរៀល
    - -ចំណូលមិនមែនសារពើពន្ធ...................................១ ០៥០ លានរៀល
  - \+ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ...............................៧៩ ២៧១ លានរៀល

  (ក្នុងនោះឧបត្ថម្ភសម្រាប់មូលនិធិសង្កាត់ចំណុះក្រុង ២០ ៨៦៦ លានរៀល)

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

សរុបចំណាយថវិកា..........................................................៨០ ៣២១ លានរៀល

+ចំណាយចរន្ត..........................................................៥៩ ៤៥៥ លានរៀល

+ចំណាយសង្កាត់ចំណុះក្រុង..........................................................២០ ៨៦៦ លានរៀល

ការបែងចែកកញ្ចប់ថវិការួមក្នុងចំណុច "ក" និងចំណុច "ខ" ខាងលើ ទៅឲ្យរាជធានី ខេត្ត ក្រុង ស្រុកនីមួយៗ តាមជំពូក គណនី និងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ១៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៨.-**

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១២

ចាស. ១២១២.១១០១

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**ហត្ថលេខា**

**គាត ឈន់**

លេខ ១០៤៦ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១២

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**សយ សុខា**